# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

លេខ ០២៦ /សសគម/១៨

ថ្ងៃ ពុធ ៨ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៨

**ប្រធានគណៈមេធាវី**

**មេធាវី សួន វិសាល**

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង ចណ្ណៈ
២-មេធាវី អ៊ុច កិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ុំ ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុភក្ខន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ថាវិត
៩-មេធាវី ជុ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃឹម
១៣-មេធាវី លឹម សុវណ្ណា
១៤-មេធាវី ឈឹម ភិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មាឧជួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពិង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួច
២៣-មេធាវី ង៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

# សេចក្ដីសម្រេច
## ស្ដីពី
## ការធ្វើប្រតិភូកម្មអំណាចក្នុងការបែងចែក និងចាត់ចែងរឿងក្ដីរបស់ជនក្រីក្រ ឱ្យទៅប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី-ខេត្ត

**ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន វិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១១
- បានឃើញសេចក្ដីសម្រេចលេខ ០២៥/សសគម/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្ដីពីគោលការណ៍ណែនាំស្ដីពីការទទួល ការបែងចែក ការគ្រប់គ្រង និងការចំណាយលើរឿងក្ដីរបស់នាយកដ្ឋានការពារក្ដីជូនជនក្រីក្រ ។

**សម្រេច**

**ប្រការ ១.-** ត្រូវបានធ្វើប្រតិភូកម្មអំណាចក្នុងការបែងចែក និងចាត់ចែងរឿងក្ដីរបស់ជនក្រីក្រ ឱ្យទៅប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី-ខេត្ត ។

**ប្រការ ២.-** ប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី-ខេត្តនីមួយៗ មានភារកិច្ចធ្វើការបែងចែក និងចាត់ចែងរឿងក្តីរបស់ជនក្រីក្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមប្រធានគណៈមេធាវី ស្របតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ០២៥/សសគម/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្តីពីគោលការណ៍ណែនាំស្តីពីការទទួល ការបែងចែក ការគ្រប់គ្រង និងការចំណាយលើការពាររឿងក្តីជូនជនក្រីក្រ ។

**ប្រការ ៣ .-** ប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី-ខេត្តនីមួយៗ មានសិទ្ធិប្រើត្រាមេធាវីលើលិខិតផ្លូវការរបស់ប្រតិភូ ស្របតាមគំរូដែលបានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ ៤ .-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-** អគ្គលេខាធិការ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានការពារក្តីជូនជនក្រីក្រ និងប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី-ខេត្ត ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**មេធាវី សួន-វិសាល**

ចម្លងជូន ៖

- -ក្រុមប្រឹក្សាគណៈមេធាវី
- -ក្រសួងយុត្តិធម៌
- -សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ ៥
- -ឯកសារ-កាលប្បវត្តិ